# Living the Lotus

## Buddhism in Everyday Life

9
2024
VOL. 228




## Members in the US, and from Japan, Join the 2024 Nisei Week Grand Parade in Los Angeles, August 11



Photos: Richard Kano

Living the Lotus
Vol. 228 (September 2024)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# ភ្ជួររាស់ស្រែបេះដូង ស្វែងរកព្រះពុទ្ធ

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## កិច្ចសន្ទនារវាងព្រាហ្មណ៍និងព្រះពុទ្ធ

នៅឆ្នាំ១៩៩៨ដែលសមាគមរីហ្សូកូសេកៃយើងឈានចូលដល់ខួបគម្រប់៦០ឆ្នាំរាប់ចាប់ពីថ្ងៃដែលបង្កើតឡើងមកខ្ញុំព្រះករុណាអាត្មាភាពបានសរសេរនៅក្នុងទស្សនាវត្តី “យ៉ាគឺស៊ីន” ( ដែលមានន័យថាការវិវឌ្ឍន៍ទៅមុខយ៉ាងខ្លាំង-បោះពុម្ពផ្សាយដោយរោងពុម្ពកូសេ ) ពីការចាំបាច់នៃការភ្ជួររាស់បេះដូងរបស់យើងម្នាក់ៗដូចតទៅ៖

“កាលពីនៅជាកុមារ ខ្ញុំព្រះករុណាអាត្មាភាពធ្លាប់បានជួយភ្ជួររាស់ស្រែចំការឪពុកម្ដាយ។ដីដែលយើងបានភ្ជួររាស់និងដីដែលមិនបានភ្ជួររាស់ វាខុសគ្នា។ដីដែលមិនបានភ្ជួររាស់វារឹងកញ្ជ្រឹសជ្រើស រកដាំអីមិនកើតទេ រីឯដីដែលបានភ្ជួររាស់ស្រួលបួលវិញទន់ល្មើយហើយឆាប់ស្រូបយកទឹកនិងជីរបានភ្លាមៗ។”

ដូចគ្នានឹងដីនេះដែរ បេះដូងដែលយើងភ្ជួររាស់ត្រឹមត្រូវល្អល្អាច់ ទ្បើងទន់ភ្លន់ គ្មានការជាប់ជំពាក់ អាចស្រូបយកអ្វីៗគ្រប់យ៉ាងដោយបានបទ។ ជាមួយនឹងគ្នានោះក៏ខ្ញុំព្រះករុណាអាត្មាភាពបានលើកយករឿងល្បើកព្រះពុទ្ធនិងគាថាដែលមាននៅក្នុងគម្ពីរសុត្តនិបាតមកបង្ហាញផងដែរ។

ខ្ញុំព្រះករុណាអាត្មាភាពសូមលើកយកមកបង្ហាញជាថ្មីម្ដងទៀតនៅទីនេះ។

លុះការងាររៀបចំភ្ជួររាស់បានចប់សព្វគ្រប់ហើយព្រាហ្មណ៍ជាកុដុម្ពីក៏ចាប់ផ្ដើមចែកស្បៀងអាហារដល់កសិករទាំងឡាយដែលបានមកជួយភ្ជួររាស់ដីឱ្យគាត់។នៅពេលនោះគាត់ក៏ក្រឡេកទៅឃើញព្រះសម្មា សម្ពុទ្ធនិមន្តបិណ្ឌបាត្រ គាត់ក៏សួរដោយពាក្យសម្ដីធ្ងន់ៗទៅកាន់ព្រះអង្គថា៖ហេតុអ្វីបានជាលោកមិនកាប់ឆ្ការភ្ជួររាស់ដីដាំដុះដើម្បីឱ្យបានអ្វីហូបចុកនឹងគេ ?ក៏ប៉ុន្តែព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបទៅព្រាហ្មណ៍វិញដោយព្រះពុទ្ធដីកាទន់ភ្លន់ថា៖អាត្មាភាពកំពុងតែកាប់ឆ្ការភ្ជួររាស់ដី ដើម្បីដាំដុះហើយទេតើ ?

ដោយសារតែព្រាហ្មណ៍ស្ដាប់ពុំយល់ន័យដែលព្រះអង្គចង់មានពុទ្ធដីកា ព្រះអង្គក៏សូត្រជាគាថាបន្ថែមថា៖

ជំនឿជាគ្រាប់ពូជដែលអាត្មាភាពសាបព្រោះ ហើយការសិក្សាបដិបត្តិដ៏លំបាក គឺជាទឹកភ្លៀង។
ប្រាជ្ញាគឺជានង្គ័លរបស់អាត្មាភាពហើយ
សេចក្ដីខ្មាសអៀនជានឹមនង្គ័ល។

បេះដូងជាខ្សែពួរសម្រាប់ចងក្រៀក ស្វ័យត្រិះរិះឬស្វ័យឆ្លុះបញ្ចាំងគឺជាគល់នង្គ័លនិងឈើសម្រាប់ឆ្កឹសដីឬធូលីចេញពីគល់នង្គ័ល ។

សម្រួមកាយនិងពាក្យសម្តី បរិភោគល្មមៗមិនជ្រុល។

គោរពសច្ចៈ គឺជាការជម្រះស្មៅរបស់អាត្មាភាព។

ភាពទន់ភ្លន់គឺការដោះលែងគោចេញពីនឹម។

សេចក្តីព្យាយាមជាគោដែលជួយដឹកអីវ៉ាន់នាំយើងទៅដល់ទីស្ងប់ស្ងាត់។

យើងដើរទៅមុខមិនរាថយក្រោយទាំងគ្មានក្តីបារម្ភរហូតដល់បានទៅដល់ទីនោះ ។

ការកាប់ឆ្ការភ្ជួររាស់ដាំដុះរបស់អាត្មាភាពគឺប្រព្រឹត្តទៅយ៉ាងនេះហើយទទួលបាននូវផ្លែផ្កាអមតៈ។

ការកាប់ឆ្ការភ្ជួររាស់ដាំដុះយ៉ាងនេះរំដោះយើងចេញពីទុក្ខនានាគ្រប់យ៉ាង ។ (『ភ្ជួររាស់ស្រែបេះដូង』／នីវ៉ាណុនីជីកុ・រោងពុម្ពកូសេ)

គាថានេះបង្ហាញស្ថានភាពនៃការភ្ជួររាស់ដើម្បីដាំដុះនៅប្រទេសឥណ្ឌានិងទីកន្លែងផ្សេងទៀតក្នុងអំឡុងពេលដែលព្រះសម្មាម្ពុទ្ធលោកមានព្រះជន្មាយុគង់នៅ។ កាលពីដើម សូម្បីតែនៅក្នុងប្រទេសជប៉ុន ក៏វិធីសាស្រ្តចម្បងនៃការដាំដុះគឺការប្រើនង្គ័លដែលជាឧបករណ៍កសិកម្ម និងសត្វពាហនៈឱ្យអូសទាញដើម្បីភ្ជួររាស់ដីស្រែឱ្យទន់ល្មើយ។

ព្រះសម្មាសម្ពុទ្ធបានប្រៀបធៀបនង្គ័លដែលចូកជីករាស់ដីស្រែ (ចិត្ត) ទៅនឹងប្រាជ្ញា ប៉ុន្តែដើម្បីឱ្យកម្លាំងអូសទាញនៃគោក្របី អាចបញ្ជូនទៅកាន់នង្គ័ល ឱ្យនង្គ័ល (ប្រាជ្ញា) អាចធ្វើការងារបានពេញលេញ គេចាំបាច់ត្រូវការនឹមដែលផ្ទាប់គោក្របីនិងនង្គ័លដើម្បីគ្រប់គ្រងគោ និងនង្គ័ល។ នៅក្នុងគាថាមានចែងថា «សេចក្តីខ្មាសអៀនគឺជានឹម» ដូច្នេះដោយសារតែមានសេចក្តីខ្មាសអៀនទើបបេះដូងអាចធ្វើស្វ័យត្រិះរិះឬស្វ័យឆ្លុះបញ្ចាំងដែលព្រះអង្គប្រដូចទៅនឹងគល់នង្គ័ល។នៅពេលដែលយើងភ្លេចស្វ័យត្រិះរិះយើងអាចប្រើឈើឆ្កឹសដីដែលកកជាប់នៅនឹងគល់នង្គ័លចេញដើម្បីឱ្យប្រាជ្ញា (នង្គ័ល) អាចនឹងធ្វើការឱ្យអស់ពីសមត្ថភាពហើយបេះដូង (ស្រែចំការ) អាចនឹងភ្ជួររាស់ដាំដុះបានយ៉ាងល្អ។

## ចំណេះដឹងទាំងអស់ពីព្រះពុទ្ធសាសនាមាននៅទីនេះ

«ព្រះសម្មាសម្ពុទ្ធ បានប្រើវិធីសាស្រ្តបង្រៀនយ៉ាងប៉ិនប្រសប់ឱ្យងាយយល់ដល់អ្នកដែលរកធ្វើការដាំដុះ គឺថាការសាបព្រោះបណ្តុះ គ្រាប់ពូជនៃជំនឿទៅក្នុងចិត្តរបស់យើងក៏ជាការចាំបាច់ដូចតែការសាបព្រោះគ្រាប់ពូជទៅលើផែនពសុធារបស់កសិករដែរ។

អ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាសាស្រ្តាចារ្យម៉ាស៊ុថានី ហ្វ៊ឺមីអូ （ Masutani Fumio）បាន សរសើរគាថានេះថាជាព្រះធម្មទេសនាដ៏ល្អមួយដែលគិតពីកម្រិតនិងវិសាលភាពនៃចំ ណេះដឹងនៃអ្នកស្តាប់។ រួចហើយបន្ទាប់ពីបានសរសើររួច លោកបានមានប្រសាសន៍ថា "រូបភាព និងខ្លឹមសារទាំងមូលនៃព្រះពុទ្ធសាសនាត្រូវបានពន្យល់នៅទីនេះយ៉ាងក្បោះក្បាយសាមញ្ញ និងជាក់ស្តែង"។ នៅពេលដែលគ្រាប់ពូជនៃជំនឿធ្លាក់ទៅលើដីនៃចិត្តរបស់អ្នក អ្នកនឹងឈានដល់ភាពសុខសាន្តគ្មានការព្រួយបារម្ភ ហើយថែមទាំងបាន "រំដោះផុតពីទុក្ខទាំងឡាយ"។

លើសពីនេះទៅទៀត បំណងប្រាថ្នារួមទាំងមធ្យោបាយដើម្បីសម្រេចបានសេចក្តីប្រាថ្នារបស់អ្នកទាំងឡាយណាដែលស្វែងរកសេចក្តីស្ងប់ស្ងាត់ នោះ ត្រូវបានបង្រួបបង្រួមជាគាថាខ្លីៗ ហើយយើងអាចស្រមៃបានថាមានមនុស្សជាច្រើនដែលបានស្តាប់ព្រះធម្មទេសនានេះ នឹងទទួលបាននូវក្តីសង្ឃឹមនិងកម្លាំងវិជ្ជមានសម្រាប់អនាគតក្នុងជីវិតរបស់ពួកគេ ។



ទោះជាយ៉ាងនេះក្តី ខ្ញុំព្រះករុណាអាត្មាភាពមិនយល់ថាការបណ្តុះបណ្តាលចិត្តត្រឹមតែមួយដង នឹងអាចធ្វើឱ្យអ្នកចាកផុតពីទុក្ខបានទេ។ សំខាន់ត្រូវបណ្តុះម្តងហើយម្តងទៀត ដោយខំស្វែងយល់ពីធាតុជាព្រះពុទ្ធរបស់អ្នកនៅរាល់ខណៈដែលអ្នកបណ្តុះនោះ ហើយកត្តានេះនឹងនាំត្រង់ឆ្ពោះទៅរកសេចក្តីស្ងប់ស្ងាត់។នៅក្នុងន័យនេះ ខ្ញុំព្រះករុណាអាត្មាភាពចង់ពិចារណាឱ្យស៊ីជម្រៅបន្តិចទៀតទៅលើការភ្ញាក់រលឹកពីធាតុជាព្រះពុទ្ធរបស់ខ្លួននេះ។

From *Kosei*, September 2024




# A Global Buddhist Movement




Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp